# សេចក្ដីពន្យល់អំពីអង្គហេតុចំបងដែលជាធាតុផ្សំ

## ~ករណីស្ដីពីការទាមទារឱ្យចុះបញ្ជីផ្ទេរកម្មសិទ្ធិដោយផ្អែកលើកិច្ចសន្យា~

នាយកដ្ឋានសហប្រតិបត្តិការអន្តរជាតិ
វិទ្យាស្ថានស្រាវជ្រាវទូទៅអំពីកិច្ចការច្បាប់
សាស្ត្រាចារ្យ Mr. Nose Kazunori

1

## រឿងក្ដីស្ដីពីការទាមទារឱ្យចុះបញ្ជីផ្ទេរកម្មសិទ្ធិដោយផ្អែកលើកិច្ចសន្យា

<ចូរសាកល្បងរៀបចំរឿងក្ដី>

1. ស្ដីពីសាលក្រមដែលទាមទារ
2. ស្ដីពីការទាមទារ
3. ស្ដីពីអង្គហេតុដែលជាមូលហេតុនៃការទាមទារ
4. ស្ដីពីការទទួលស្គាល់ ឬមិនទទួលស្គាល់, ស្ដីពីការតវ៉ារបស់ចុងចម្លើយ
5. ស្ដីពីការតវ៉ាតបរបស់ដើមចោទ

2

# 1. សាលក្រមដែលទាមទារ

"ពាក់ព័ន្ធនឹងដីដែលមានចុះក្នុងបញ្ជីសារពើភ័ណ្ឌឧបសម្ព័ន្ធ ចុងចម្លើយត្រូវធ្វើនីតិវិធីចុះបញ្ជីផ្ទេរកម្មសិទ្ធិដែលមានចុះក្នុងបញ្ជីសារពើភ័ណ្ឌឧបសម្ព័ន្ធស្ដីពីការចុះបញ្ជី ដោយមូលហេតុលក់ទិញនៃថ្ងៃទី20 ខែតុលា ឆ្នាំ2014"។

※សាលក្រមទទួលស្គាល់នៃរឿងក្ដីទាមទារនូវការចុះបញ្ជីផ្ទេរកម្មសិទ្ធិ គឺជាសាលក្រមទាមទារឱ្យបង្ហាញឆន្ទៈ ដូច្នេះ មិនអាចភ្ជាប់នូវការប្រកាសឱ្យអនុវត្តជាបណ្ដោះអាសន្នបានទេ។

3

## រឿងក្ដីស្ដីពីការទាមទារឱ្យចុះបញ្ជីផ្ទេរកម្មសិទ្ធិដោយផ្អែកលើកិច្ចសន្យា

<ចូរសាកល្បងរៀបចំរឿងក្ដី>

1. ស្ដីពីសាលក្រមដែលទាមទារ
2. ស្ដីពីការទាមទារ
3. ស្ដីពីអង្គហេតុដែលជាមូលហេតុនៃការទាមទារ
4. ស្ដីពីការទទួលស្គាល់ ឬមិនទទួលស្គាល់, ស្ដីពីការតវ៉ារបស់ចុងចម្លើយ
5. ស្ដីពីការតវ៉ាតបរបស់ដើមចោទ

4

## 2. ការទាមទារ

សិទ្ធិទាមទារឱ្យចុះបញ្ជីផ្ទេរកម្មសិទ្ធិ ដោយផ្អែកលើកិច្ចសន្យាលក់ទិញ

5

## រឿងក្តីស្តីពីការទាមទារឱ្យចុះបញ្ជីផ្ទេរកម្មសិទ្ធិ ដោយផ្អែកលើកិច្ចសន្យា

<ចូរសាកល្បងរៀបចំរឿងក្តី>

1. ស្តីពីសាលក្រមដែលទាមទារ
2. ស្តីពីការទាមទារ
3. ស្តីពីអង្គហេតុដែលជាមូលហេតុនៃការទាមទារ
4. ស្តីពីការទទួលស្គាល់ ឬមិនទទួលស្គាល់, ស្តីពីការតវ៉ារបស់ចុងចម្លើយ
5. ស្តីពីការតវ៉ាតបរបស់ដើមចោទ

6

## 3-1. អង្គហេតុដែលជាមូលហេតុនៃការទាមទារ

A) XនិងY បានបង្កើតកិច្ចសន្យាលក់ទិញ

"នៅពេលបង្កើតកិច្ចសន្យាលក់ទិញ Yជាកម្មសិទ្ធិករនៃវត្ថុដែលជាកម្មវត្ថុនោះ" ឬ "ក្នុងបញ្ជី មានឈ្មោះY ជាម្ចាស់កម្មសិទ្ធិ" មិនមែនជាមូលហេតុនៃការទាមទារទេ។ (យោង: មាត្រា531 ស្តីពីការលក់វត្ថុរបស់អ្នកដទៃ)។

B) ពេលបង្កើតកិច្ចសន្យាលក់ទិញនៃA) XនិងYបានធ្វើជាលិខិតយថាភូត(មាត្រា336 កថាខ័ណ្ឌទី2)។

7

## 3-2. អង្គហេតុដែលជាមូលហេតុនៃការទាមទារ

ឧទាហរណ៍នៃការសរសេរអំពីអង្គហេតុ

A) នៅថ្ងៃទី20 ខែតុលា ឆ្នាំ2014 ដើមចោទបានទិញដី (ដែលមានចុះក្នុងបញ្ជីសារពើភ័ណ្ឌឧបសម្ព័ន្ធ) ពីចុងចម្លើយ ក្នុងតម្លៃ20ម៉ឺនដុល្លារ។

B) នៅថ្ងៃដដែលនេះ ដើមចោទនិងចុងចម្លើយបានបង្កើតលិខិតយថាភូតស្តីពី A)។

8

## រឿងក្ដីស្ដីពីការទាមទារឱ្យចុះបញ្ជីផ្ទេរកម្មសិទ្ធិ ដោយផ្អែកលើកិច្ចសន្យា

<ចូរសាកល្បងរៀបចំរឿងក្ដី>

1. ស្ដីពីសាលក្រមដែលទាមទារ
2. ស្ដីពីការទាមទារ
3. ស្ដីពីអង្គហេតុដែលជាមូលហេតុនៃការទាមទារ
4. ស្ដីពីការទទួលស្គាល់ ឬមិនទទួលស្គាល់, ស្ដីពីការតវ៉ារបស់ចុងចម្លើយ
5. ស្ដីពីការតវ៉ាតបរបស់ដើមចោទ

9

## 4-1. ការទទួលស្គាល់ ឬមិនទទួលស្គាល់

A) XនិងYបានបង្កើតកិច្ចសន្យាលក់ទិញ
→ទទួលស្គាល់

B) XនិងYបានបង្កើតលិខិតយថាភូត នៅពេលលក់ទិញនៃ A)
→ទទួលស្គាល់

10

# 4-2-1. ការតវ៉ា

## ការរំលាយដោយសារការមិនអនុវត្តកាតព្វកិច្ច

A) ការកន្លងផុតទៅនៃកាលកំណត់បង់ថ្លៃលក់ទិញ(មាត្រា408 កថាខ័ណ្ឌទី1 ចំណុច ក.)

1) កាលកំណត់បង់ថ្លៃលក់ទិញគឺ ថ្ងៃទី25 ខែតុលា ឆ្នាំ2014

2) កាលកំណត់បង់ថ្លៃលក់ទិញ បានកន្លងផុតទៅ

B) បានដាស់តឿនឱ្យបង់ថ្លៃលក់ទិញ(មាត្រា408 កថាខ័ណ្ឌទី1 ចំណុច ក. )

1)បានដាស់តឿនដោយកំណត់អំឡុងពេលសមស្របមួយ ក្រោយពេលកន្លងផុតទៅនៃកាលកំណត់បង់

2)ក្រោយការដាស់តឿន អំឡុងពេលកំណត់សមស្របនោះបានកន្លងផុតទៅ(មាត្រា408 កថាខ័ណ្ឌទី1 ចំណុច ក. )

C) បានបង្ហាញឆន្ទៈរំលាយកិច្ចសន្យា ក្រោយពេលកន្លងផុតទៅនៃអំឡុងពេល(មាត្រា409)

D) ការឃើតយ៉ាវ គឺជាអំពើខុសច្បាប់(≒ពុំមានសិទ្ធិតវ៉ាឱ្យអនុវត្តព្រមគ្នា)

11

# 4-1-2. ការតវ៉ា

## ការរំលាយកិច្ចសន្យាដោយសារការមិនអនុវត្តកាតព្វកិច្ច

A) សេចក្ដីពន្យល់បន្ថែមអំពី "ការបានដាស់តឿនឱ្យបង់ថ្លៃលក់ទិញ"

កំណើតនៃការបង់ថ្លៃលក់ទិញ គឺជាមូលដ្ឋាននៃមូលហេតុនៃការទាមទារ ដូច្នេះហើយ មិនចាំបាច់និយាយអំពីចំណុចនេះនៅក្នុងការតវ៉ាទេ។

12

# 4-2-3. ការតវ៉ា

ការរំលាយកិច្ចសន្យាដោយសារការមិនអនុវត្តកាតព្វកិច្ច

D) សេចក្តីពន្យល់បន្ថែមអំពី "ការយឺតយ៉ាវ គឺជាអំពើខុសច្បាប់"

ការអះអាងអំពីអង្គហេតុនៃការបង្កើតកិច្ចសន្យាលក់ទិញ នឹងបង្កើតឱ្យមានសិទ្ធិតវ៉ាឱ្យអនុវត្តព្រមគ្នា ពាក់ព័ន្ធនឹងកាតព្វកិច្ចបង់ប្រាក់របស់ភាគីម្ខាងទៀត។ គេបកស្រាយថា សិទ្ធិតវ៉ាឱ្យអនុវត្តព្រមគ្នា គឺជាមូលហេតុដែលធ្វើឱ្យការយឺតយ៉ាវក្នុងការអនុវត្តបានរួចផុតពីភាពខុសច្បាប់ (ទស្សនៈអានុភាពនៃអត្ថិភាព=ឱ្យតែមានអត្ថិភាព នឹងមានអានុភាព) ហេតុនេះហើយ Y ដែលបានអះអាងអំពីការរំលាយកិច្ចសន្យា ត្រូវអះអាងអំពីអង្គហេតុដែលជាឧបសគ្គនៃកំណើតនៃសិទ្ធិតវ៉ាឱ្យអនុវត្តព្រមគ្នា និងអង្គហេតុរំលត់។

Ex.ការអនុវត្តជាមុន, ការផ្តល់នូវការអនុវត្ត ជាដើម

13

# 4-2-4. ការតវ៉ា

ឧទាហរណ៍នៃការសរសេរអំពីអង្គហេតុ

A) ការកន្លងផុតទៅនៃកាលកំណត់ឱ្យបង់ថ្លៃលក់ទិញ+ការអនុវត្តមុន

1)ក្នុងកិច្ចសន្យាលក់ទិញនៃរឿងក្តីនេះ ដើមចោទនិងចុងចម្លើយបានព្រមព្រៀងថា ត្រូវបង់ថ្លៃលក់ទិញនៅថ្ងៃទី25 ខែតុលា ឆ្នាំ2014 ហើយត្រូវធ្វើនីតិវិធីចុះបញ្ជីផ្ទេរកម្មសិទ្ធិ នៅថ្ងៃទី26 ខែដដែល។

2) ថ្ងៃទី25 ខែតុលា ឆ្នាំ2014បានកន្លងផុតទៅ។

B) ការដាស់តឿន និង ការបង្ហាញឆន្ទៈរំលាយកិច្ចសន្យា

1)នៅថ្ងៃទី1 ខែវិច្ឆិកា ឆ្នាំ2014 ចុងចម្លើយបានដាស់តឿនឱ្យដើមចោទបង់ថ្លៃលក់ទិញ 20ម៉ឺនដុល្លារ យ៉ាងយឺតត្រឹមថ្ងៃទី10 ខែដដែល ហើយបានបង្ហាញឆន្ទៈថា រំលាយកិច្ចសន្យាលក់ទិញនៃរឿងក្តីនេះ បើសិនជាដើមចោទមិនបានបង់ទេ។

2)ថ្ងៃទី10 ខែវិច្ឆិកា ឆ្នាំ2014បានកន្លងផុតទៅ។

14

## រឿងក្ដីស្ដីពីការទាមទារឱ្យចុះបញ្ជីផ្ទេរកម្មសិទ្ធិដោយផ្អែកលើកិច្ចសន្យា

<ចូរសាកល្បងរៀបចំរឿងក្ដី>

1. ស្ដីពីសាលាក្រមដែលទាមទារ
2. ស្ដីពីការទាមទារ
3. ស្ដីពីអង្គហេតុដែលជាមូលហេតុនៃការទាមទារ
4. ស្ដីពីការទទួលស្គាល់ ឬមិនទទួលស្គាល់, ស្ដីពីការតវ៉ារបស់ចុងចម្លើយ
5. ស្ដីពីការតវ៉ាតបរបស់ដើមចោទ

15

## 5-1. ការទទួលស្គាល់ឬមិនទទួលស្គាល់

A) ក្នុងកិច្ចសន្យាលក់ទិញនៃរឿងក្ដីនេះ ដើមចោទនិងចុងចម្លើយបានព្រមព្រៀងថា ត្រូវបង់ថ្លៃលក់ទិញនៅថ្ងៃទី25 ខែតុលា ឆ្នាំ 2014 ហើយត្រូវធ្វើនីតិវិធីចុះបញ្ជីផ្ទេរកម្មសិទ្ធិ នៅថ្ងៃទី26 ខែដដែល។

→ទទួលស្គាល់

ថ្ងៃទី25 ខែតុលា ឆ្នាំ2014 បានកន្លងផុតទៅ។

→អង្គហេតុជាក់ស្ដែង

B) នៅថ្ងៃទី1 ខែវិច្ឆិកា ឆ្នាំ2014 ចុងចម្លើយបានដាស់តឿនឱ្យដើមចោទបង់ថ្លៃលក់ទិញ 20ម៉ឺនដុល្លារ យ៉ាងយឺតត្រឹមថ្ងៃទី10 ខែដដែល ហើយបានបង្ហាញឆន្ទៈថា រំលាយកិច្ចសន្យាលក់ទិញនៃរឿងក្ដីនេះ បើសិនជាដើមចោទមិនបានបង់ទេ។

→ទទួលស្គាល់

ថ្ងៃទី10 ខែវិច្ឆិកា ឆ្នាំ2014 បានកន្លងផុតទៅ។

→ អង្គហេតុជាក់ស្ដែង

16

# 5-2-1. ការតវ៉ាតបទី១

ការសង(ការអនុវត្តតាវកាលិកតប)

A) Xបានផ្តល់តាវកាលិកចំពោះY ទៅតាមគោលគំនិតដើមនៃកាតព្វកិច្ច

B) ការផ្តល់តាវកាលិកនៃA) ត្រូវបានធ្វើឡើងចំពោះសិទ្ធិលើបំណុលនោះតែម្តង

17

# 5-2-2. ការតវ៉ាតបទី១

ឧទាហរណ៍នៃការសរសេរអំពីអង្គហេតុ

Xបានបង់ថ្លៃលក់ទិញដីនៃរឿងក្តីនេះ ជាសាច់ប្រាក់ចំនួន 20ម៉ឺនដុល្លារ ទៅឱ្យY តាមរយៈ Z នៅថ្ងៃទី24 ខែតុលា ឆ្នាំ2014។

18

## 5-3-1. ការតវ៉ាតបទី២

ការសងចំពោះអ្នកដែលមើលទៅហាក់ដូចជាម្ចាស់បំណុល (មាត្រា439)

A) Zត្រូវមានភិនភាគដែលមើលទៅហាក់ដូចជាបែសកជនរបស់ម្ចាស់បំណុល

B) Xបានជឿជាក់ថា Z ជាបេសកជនរបស់ Y

C) ស្តីពីការជឿជាក់ក្នុងចំណុច B) នេះ Xពុំមានកំហុសធ្ងន់ធ្ងរទេ

D) Xបានបង់ទៅឱ្យZដែលបានប្រាប់ថា គាត់ជាបេសកជនរបស់ Y

19

## 5-3-2. ការតវ៉ាតបទី២

ឧទាហរណ៍នៃការសរសេរអំពីអង្គហេតុ

A) Zបានប្រាប់ទៅ X ថា គាត់មកទទួលប្រាក់ក្នុងនាមជាបេសកជនរបស់ Y។

B) Xបានជឿថា Z ជាបេសកជនរបស់ Y។

C) Z គឺជាកូនក្មួយរបស់ Y។

Zបានធ្វើជាឈ្មួញកណ្តាលរវាង XនិងY តាំងពីដំបូង ហើយមានវិភាគទានក្នុងការបង្កើតកិច្ចសន្យាលក់ទិញនេះ។ Z មានវិក័យប័ត្រដែលមានហត្ថលេខារបស់ Y។

D) នៅថ្ងៃទី24 ខែតុលា ឆ្នាំ2014 Xបានបង់ប្រាក់20ម៉ឺនដុល្លារទៅឱ្យZដែលបាននិយាយថា គេជាបេសកជនរបស់ Y។

20

# 5-3-3. ការតវ៉ាតបទី២

ការទទួលស្គាល់ ឬមិនទទួលស្គាល់របស់ Y

A) Zបានប្រាប់ទៅ X ថា គាត់មកទទួលប្រាក់ក្នុងនាមជាបេសកជនរបស់ Y ។

→មិនដឹង

B) Xបានជឿថា Z ជាបេសកជនរបស់ Y។

→មិនដឹង

C) Z ជាក្មួយរបស់ Y។

→ទទួលស្គាល់

Z បានធ្វើជាឈ្មួញកណ្តាលរវាង XនិងY តាំងពីដំបូង ហើយមានវិភាគទានក្នុងការបង្កើតកិច្ចសន្យាលក់ទិញនេះ។

→មិនដឹង

Z មានវិក័យប័ត្រដែលមានហត្ថលេខារបស់ Y។

→មិនដឹង

21




កិច្ចសន្យា
លក់ទិញ
ការរំលាយកិច្ចសន្យា
ដោយការមិនអនុវត្ត
កាតព្វកិច្ច
ការសង
ការសងចំពោះ
ឧបភោគី
23